ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ០០៧៥ សណន

ថ្ងៃចន្ទ ១៤ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ មេសា ឆ្នាំ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## ការលើកកម្ពស់ការយកចិត្តទុកដាក់ក្នុងការបង្ការ និងការពន្លត់អគ្គិភ័យ នៅក្នុងឧស្សាហកម្មទេសចរណ៍

ក្នុងស្មារតីបុរេសកម្មបំពេញករណីយកិច្ចចូលរួមក្នុងសកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ក៏ដូចជាយកចិត្តទុកដាក់ជាចម្បងលើសុវត្ថិភាព ការការពារអាយុជីវិត និងការបង្ការការខាតបង់ទ្រព្យសម្បត្តិដោយចៃដន្យពីគ្រោះថ្នាក់អគ្គិភ័យណាមួយ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ ដូចខាងក្រោម៖

១- បង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ការ និងទប់ស្កាត់ការកើតឡើងនៃគ្រោះថ្នាក់អគ្គិភ័យ ដើម្បីធានាបានសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរ ដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍ និងច្បាប់ស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

២- ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវដោយផ្ទាល់ក្នុងការបង្ការនិងពន្លត់អគ្គិភ័យនៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍របស់ខ្លួន

៣- ត្រូវប្រាកដថាប្រព័ន្ធបង្ការអគ្គិភ័យ និងឧបករណ៍ពន្លត់អគ្គិភ័យនៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍របស់ខ្លួនស្ថិតក្នុងលក្ខខណ្ឌល្អអាចប្រើប្រាស់ និងអាចឆ្លើយតបគ្រោះអគ្គិភ័យបានភ្លាមៗ និងមានប្រសិទ្ធភាព

៤- ត្រូវអនុវត្តតាមលក្ខខណ្ឌ និងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យរបស់ក្រសួងមានសមត្ថកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ចំពោះរាល់ការស្តុក ឬការប្រើប្រាស់សារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ ដែលអាចបង្កឱ្យមានអគ្គិភ័យ

៥- ត្រូវរៀបចំច្រកចេញក្នុងគ្រាអាសន្ននៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍របស់ខ្លួនឱ្យស្របតាមច្បាប់កំណត់ និងត្រូវធានាថាមិនមានឧបសគ្គណាមួយ ឬក៏មានអ្វីរាំងនៅច្រកចេញក្នុងគ្រាអាសន្ននោះឡើយ

៦- ត្រូវជូនដំណឹងដល់អាជ្ញាធរដែនដី និងសុំជំនួយពន្លត់អគ្គិភ័យពីអង្គភាពនគរបាលពន្លត់អគ្គិភ័យឱ្យបានឆាប់បំផុត ក្នុងករណីកើតមានគ្រោះថ្នាក់អគ្គិភ័យនៅក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍របស់ខ្លួន

៧-ត្រូវសហការជាមួយអង្គភាពនគរបាលបង្ការ និងពន្លត់អគ្គិភ័យដើម្បីធ្វើផែនការបង្ការពន្លត់អគ្គិភ័យ និងជម្លៀសមនុស្សចេញក្នុងករណីមានអគ្គិភ័យកើតឡើង ប្រសិនបើមានគម្រោងរៀបចំពិធីធំៗណាមួយដែលប្រមូលផ្ដុំមនុស្សច្រើនកុះករ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ និងផ្នែកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់បំពេញករណីយកិច្ចចូលរួមក្នុងសកម្មភាពបង្ការ និងពន្លត់អគ្គិភ័យប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

រដ្ឋមន្ត្រី

សុខ សុខេន

កន្លែងទទួល៖

- រដ្ឋបាលរាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- គ្រប់សមាគមឧស្សាហកម្មទេសចរណ៍
- ឯកសារ កាលប្បវត្តិ